ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ............................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១
## និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា
### នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២

**សូមគោរព :**

- **គណៈអធិបតី**
- **លោក Robert Beerens ជំនាញការនៅធនាគារជាតិនៃកម្ពុជា**
- **លោក Ye-Hong Ahn ជំនាញការធនាគារកណ្តាលកូរ៉េ នៅធនាគារជាតិនៃកម្ពុជា**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា ជាមួយលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា នាពេលនេះ ។ ជារៀងរាល់ឆ្នាំ ធនាគារជាតិនៃកម្ពុជាយើងតែងតែរៀបចំប្រារព្ធពិធីនេះឡើង ដើម្បីផ្សព្វផ្សាយ និងអបអរសាទរចំពោះលទ្ធផលការងាររបស់ខ្លួនដែលសម្រេចបាន ។ សន្និបាតរបស់យើងថ្ងៃនេះ ត្រូវបានរៀបចំឡើង បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភា កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងព្រមទាំងទទួលស្គាល់ដោយអ្នកអង្កេតការជាតិ-អន្តរជាតិ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងខ្លាំង ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ កសាងសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។


ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលការងារសំខាន់ៗ របស់ធនាគារជាតិនៃកម្ពុជានៅឆមាសទី១ ឆ្នាំ២០១៣ ដូចតទៅ ៖

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

តាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅឆមាសទី១ ឆ្នាំ២០១៣ សេដ្ឋកិច្ចពិភពលោកនៅតែបន្តកើនឡើងក្នុងល្បឿនយឺត ដោយសារការមិនទាន់ងើបឡើងវិញនៃសេដ្ឋកិច្ចតំបន់អឺរ៉ូ កំណើនយឺតនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងសន្ទុះកំណើននៃប្រទេសកំពុងងើបឡើងសំខាន់ៗមួយចំនួន ដូចជា ប្រទេសចិន និងឥណ្ឌា បានទទួលរងស្ថានភាពចុះទន់ខ្សោយនៃតម្រូវការ ទាំងក្នុងនិងក្រៅប្រទេស ។ ប៉ុន្តែ ដំណើរការសេដ្ឋកិច្ចពិភពលោកនៅឆមាសទី២ ត្រូវបានរំពឹងថាមានភាពប្រសើរជាងឆមាសទី១ បន្តិច ។

ស្ថិតក្នុងស្ថានភាពនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើការព្យាករណ៍កំណើនសេដ្ឋកិច្ចពិភពលោក មកត្រឹម ៣,១% នៅឆ្នាំ២០១៣ ស្មើនឹងអត្រាឆ្នាំ២០១២ ដែរ ។ ក្នុងនោះ កំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ នឹងកើន ១,២% ហើយប្រទេសកំពុងងើបឡើងនិងប្រទេសកំពុងអភិវឌ្ឍន៍នឹងមានកំណើន ៥% ។ ដោយឡែក សេដ្ឋកិច្ចប្រទេសអាស៊ាន ៥ នឹងរក្សាកំណើនខ្ពស់ប្រមាណ ៥,៦%។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ បានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ បានបន្តបង្ហាញសញ្ញាល្អប្រសើរ ដោយការនាំចេញ វិស័យទេសចរណ៍ និងកសិកម្មមានកំណើនរឹងមាំ ហើយវិស័យអចលនទ្រព្យនិងសំណង់ បានងើបឡើងជាលំដាប់ ។ ផ្អែកលើស្ថានភាពល្អប្រសើរនេះ រាជរដ្ឋាភិបាលបានព្យាករដោយសុទិដ្ឋិនិយមថា សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៧,៦% ក្នុងឆ្នាំ២០១៣នេះ ហើយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយចំនួន ក៏បានកែប្រែការព្យាករលើកំណើនសេដ្ឋកិច្ចកម្ពុជាខ្ពស់ជាងមុនផងដែរ ។ កំណើននេះគាំទ្រដោយវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស គួបផ្សំនឹងការអនុវត្តគោលនយោបាយត្រឹមត្រូវ របស់រាជរដ្ឋាភិបាល ក្នុងការធ្វើពិពិធកម្មវិស័យផលិតកម្ម ជាពិសេសវិស័យកសិកម្ម និងពិពិធកម្មទីផ្សារនាំចេញផង ពិតជាបានរួមចំណែកគាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ។

ទន្ទឹមនេះ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្ម ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយប្តូរប្រាក់ប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្ន ដោយផ្អែកលើវឌ្ឍនភាពនៃសកម្មភាពសេដ្ឋកិច្ចជាតិ និងបម្រែបម្រួលនៃសេដ្ឋកិច្ចពិភពលោក ។

## II/- លទ្ធផលការងារសំខាន់ៗដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន

ដើម្បីរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រកបដោយចីរភាព ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា បានខិតខំបំពេញតួនាទីរបស់ខ្លួន ក្នុងការរក្សាស្ថិរភាពថ្លៃ ប្រកបដោយប្រសិទ្ធភាព ដោយរក្សាបាននូវស្ថិរភាពនៃតម្លៃប្រាក់រៀល និងអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក និងគ្រប់គ្រងអត្រាអតិផរណាឱ្យមានកម្រិតទាប ប្រែប្រួលក្នុងកម្រិតមួយអាចគ្រប់គ្រងបាន ។ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាស្ថិរភាពល្អប្រសើរ សម្រាប់គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។

សមិទ្ធផលទាំងនេះអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ ដូចខាងក្រោម ៖

នៅក្នុងឆមាសទី១ ឆ្នាំ២០១៣នេះ បើគិតជាមធ្យមក្នុងរយៈពេល ៦ខែ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារបានឡើងថ្លៃ ប្រមាណ ០,៧% ធៀបនឹងគ្រាដូចគ្នាក្នុងឆ្នាំ២០១២ ។ ចំណែកអតិផរណារួមឆ្នាំលើឆ្នាំ នាដំណាច់ឆមាសទី១នេះ ស្មើនឹង ២,៩% ធៀបនឹង ១,៨% នៅគ្រាដូចគ្នាឆ្នាំ២០១២ ។ ជារួម អតិផរណាស្ថិតក្នុងកម្រិតទាបក្រោម ៣% ដែលជាកម្រិតមួយអាចគ្រប់គ្រងបាន ។ រូបិយវត្ថុទូទៅ (M2) មានកំណើនឆ្នាំលើឆ្នាំ ១១% ដោយភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុមានកម្រិតប្រមាណ ៥៣% នៅខែមិថុនា ឆ្នាំ២០១៣ ធៀបនឹង ៤៩% នាគ្រាដូចគ្នានៅឆ្នាំមុន ដែលឆ្លុះបញ្ចាំងពីតួនាទីនៃវិស័យធនាគារដែលកាន់តែមានសារៈសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ទុនបម្រុងអន្តរជាតិដុល បានកើនឡើងរហូតដល់ ៤.០៤៦ លានដុល្លារអាមេរិក កើនឡើង ១៣,៤% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២ ដែលអាចធានាការនាំចូលបានចំនួន ប្រមាណ ៤ខែ ។ ការគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន ស្របតាមភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ចជាតិ ។ ស្ថិរភាពថ្លៃ និងតម្លៃប្រាក់រៀល បានរួមចំណែកពង្រឹងជំនឿ ទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម ៖

**១/- វិស័យធនាគារ** : វិស័យនេះមានការអភិវឌ្ឍនិងរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ និងបានដើរតួនាទីកាន់តែសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ផ្នែកវិសាលភាពនាពេលបច្ចុប្បន្ននេះ ធនាគារពាណិជ្ជមានចំនួន៣៤

ធនាគារឯកទេសចំនួន៧ ការិយាល័យតំណាងធនាគារបរទេស៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣៧ ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ ត្រូវបាន អនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីចំនួន៣៨ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន១ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា១ និងអ្នកដំណើការតតិយភាគី៤ ។

ចំពោះទំហំប្រតិបត្តិការវិញ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារបានកើនឡើង ២៥,៦% និងឥណទានដល់វិស័យឯកជនបានកើនឡើង ៣២,៧% ធៀបនឹងគ្រាដូចគ្នានៅឆ្នាំ២០១២ ។ ការវិវត្តរីកចម្រើននេះគួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នផងនោះ បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះមកនៅកម្រិត ២,៣% ដែលបង្ហាញពីគុណភាពល្អនៃទ្រព្យសកម្មរបស់វិស័យធនាគារ ។ ដើម្បីរក្សាបាននិរន្តរភាពនៃការអភិវឌ្ឍប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា បានលើកកម្ពស់ជាប្រចាំនូវសមត្ថភាព និងវិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ។

**២/- វិស័យមីក្រូហិរញ្ញវត្ថុ** : មានការរីកចម្រើនយ៉ាងខ្លាំង ត្រូវបានគេចាត់ទុកថាជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ឥណទានផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុបានបន្តកើនឡើងគួរឲ្យកត់សម្គាល់ ដោយសមតុល្យឥណទានសរុបកើនឡើងដល់ ៤.៥១២,៣ ពាន់លានរៀល ដែលត្រូវបានផ្តល់ដល់អតិថិជនចំនួនជាង ១,៣ លាននាក់ ពោលគឺកើនឡើង ២៤,៧% និង១,៤% រៀងគ្នាធៀបនឹងរយៈពេលដូចគ្នា ។ ប្រាក់បញ្ញើវិញបានកើតដល់ ១.៦៦២,៤ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ១,១ លាននាក់ ពោលគឺកើនឡើង ៥២% និង ៦០,២ រៀងគ្នា។

ការរីកចម្រើននេះ បានរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។

**៣/- ការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** : ខណៈដែលវិស័យហិរញ្ញវត្ថុមានភាពប្រទាក់ក្រឡាគ្នា និងប្រឈមនឹងហានិភ័យនៃវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិកម្ម បានពង្រឹងការត្រួតពិនិត្យសុខភាពគ្រឹះស្ថានធនាគារជាប់ជាប្រចាំ តាមរយៈការចុះទៅត្រួតពិនិត្យដល់ទីកន្លែងនិងត្រួតពិនិត្យលើឯកសារ ក្នុងបំណងដើម្បីជួយពង្រឹងអភិបាលកិច្ចល្អនិងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ។ គិតត្រឹមឆមាសទី១ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន៧ ធនាគារឯកទេសចំនួន១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៤ និងប្រតិបត្តិករឥណទានជនបទចំនួន១ ។

ជារួម យើងបានពិនិត្យឃើញថា ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារមានភាពល្អប្រសើរនិងគោរពតាមវិធានការប្រុងប្រយ័ត្ន ក្នុងនោះ អនុបាតសាធនភាពជាមធ្យមមានប្រមាណ ២៦% លើសពីកម្រិតតម្រូវការអប្បបរមា ១៥% ហើយអនុបាតសន្ទនីយភាពមានចំនួន ៨២,២% លើសពីកម្រិតតម្រូវការអប្បរមា ៥០%។ ចំពោះគ្រឹះស្ថានធនាគារមួយចំនួនដែលមានចំណុចខ្វះខាត យើងបានផ្តល់អនុសាសន៍ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយ តាមស្ថានភាពជាក់ស្តែងផងដែរ ។

**៤/- ការពង្រឹងអភិបាលកិច្ចល្អ** : ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចឱ្យស្របតាមគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា ដាក់ចេញនូវបទប្បញ្ញត្តិនានា និងបណ្តុះបណ្តាលសមត្ថភាពជំនាញរបស់មន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ។ ជាក់ស្តែង នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចេញផ្សាយរបាយការណ៍សវនកម្មរបស់សាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម ។ ជាមួយគ្នានេះដែរ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក៏បានចេញផ្សាយរបាយការណ៍សវនកម្មសម្រេចនិងសេចក្តីសង្ខេបរបាយការណ៍ នៅខុទ្ទកាល័យលើការងារគ្រប់គ្រងសម្ភារៈការិយាល័យ និងនៅនាយកដ្ឋានប្រតិបត្តិការលើប្រតិបត្តិការផ្ទេរប្រាក់ ។

ចំពោះការងារអធិការកិច្ចវិញ យើងបានចុះត្រួតពិនិត្យនៅសាខាធនាគារជាតិនៃកម្ពុជា បានចំនួន៥ ដោយផ្តោតជាសំខាន់ទៅលើការធានាសុវត្ថិភាពឃ្លាំងប្រាក់ ការគ្រប់គ្រងសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញ ដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវុឌ្ឍិ វិន័យការងាររបស់មន្ត្រីបុគ្គលិក និងប្រសិទ្ធភាពការងារនៅតាមសាខា ឱ្យកាន់តែប្រសើរ ។

**៥/- ការអភិវឌ្ឍទីផ្សារអន្តរធនាគារ** : បច្ចុប្បន្ន យើងកំពុងរៀបចំយន្តការអនុវត្តតាមលក្ខណៈបច្ចេកទេស បណ្តុះបណ្តាលធនធានមនុស្ស កសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងមូលដ្ឋានគតិយុត្តជាដើម ខណៈដែលទីផ្សារមូលបត្រនិងទីផ្សារទុននៅកម្ពុជាបានដំណើរការនាពេលថ្មីៗនេះ ដើម្បីបង្កើនជំនឿទុកចិត្តនិងឱ្យគ្រឹះស្ថានធនាគារនិងធនាគារខ្ចីគ្នា នៅពេលដែលជួបបញ្ហាខ្វះខាតសន្ទនីយភាព ។

**៦/- ការអភិវឌ្ឍប្រព័ន្ធជាតិទូទាត់**: បច្ចុប្បន្នប្រព័ន្ធទូទាត់នៅកម្ពុជា មានប្រព័ន្ធជាតិផាត់ទាត់ ដែលបានដាក់ឲ្យដំណើរការកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ដែលអាចផាត់ទាត់ទាំងមូលបត្រ និងឧបករណ៍បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក ដូចជា ការផ្ទេរឥណទាន (Credit Remittance) ឥណទានផ្ទាល់ (Direct Credit) និងឥណពន្ធផ្ទាល់ (Direct Debit) ជាដើម ។ ដើម្បីសម្រួលដល់កិច្ចដំណើរការផាត់ទាត់ឲ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជា បានរៀបចំឯកសារវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ សម្រាប់ជាគោលការណ៍មូលដ្ឋាន ក្នុងការប្រតិបត្តិនិងអនុវត្តរបស់សមាជិក និងសភាផាត់ទាត់ជាតិ ។

**៧/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ដើម្បីបន្តអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ជំហានទី២ យើងបានពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួន ដោយបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា បណ្តុះបណ្តាលផ្នែកការងារប្រតិបត្តិការនិងជំនាញ IT និងរៀបចំការងារចាត់តាំងមន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ស្របតាមការងារជាក់ស្តែង ។

ក្រៅពីនេះ យើងបានបន្តតាមដានការអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) នៅតាមសាខារាជធានី-ខេត្ត ព្រមទាំងបន្តបណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែកបច្ចេកទេសនិងការងារគ្រប់គ្រងត្រូវបានពង្រឹង ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិជាលក្ខណៈទ្វេភាគីនិងពហុភាគីវិញ ធនាគារជាតិនៃកម្ពុជា មានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ ហើយសម្រេចបានសមិទ្ធផលដូចតទៅ ៖

**១/- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)** : ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជាចំនួន ៣លើក ។ លើកទី១ ជាបេសកកម្មជំនួយបច្ចេកទេសនៃនាយកដ្ឋានទីផ្សារមូលធននិងរូបិយវត្ថុ ចាប់ពីថ្ងៃទី១១-១៨ ខែមីនា ឆ្នាំ២០១៣ ដើម្បីសិក្សានិងវាយតម្លៃពីស្ថានភាពនៃស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា នាពេលបច្ចុប្បន្ន ។ លើកទី២ ជាបេសកកម្មរបស់មន្ត្រីមូលនិធិរូបិយវត្ថុអន្តរជាតិ ចាប់ពីថ្ងៃទី២២ ខែមេសា ដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៣ ដើម្បីពិនិត្យឡើងវិញអំពីយុទ្ធសាស្ត្រសកម្មភាពការងារ ក្នុងការបន្តពង្រឹងគុណភាពចងក្រងស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិ តាមវិធីសាស្ត្រចងក្រងថ្មី របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានបោះផ្សាយលើកទី៦ ។ លើកទី៣ ចាប់ពីថ្ងៃទី៦-១០ ខែឧសភាឆ្នាំ២០១៣ ពិនិត្យការវិវត្តរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ច និងពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នៅឆ្នាំ២០១៣ ដោយផ្តោតសំខាន់លើ (១). ទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចក្នុងឆ្នាំ២០១៣ (២). គោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ និងស្ថានភាពរូបិយវត្ថុ (៣).បញ្ហាទាក់ទងនឹងប្រតិបត្តិការរូបិយវត្ថុ និងវឌ្ឍនភាពក្នុងការពង្រឹងក្របខ័ណ្ឌរូបិយវត្ថុបច្ចុប្បន្ន (៤).ការងារទាក់ទងនិងត្រួតពិនិត្យធនាគារ ភាពរឹងមាំវិស័យហិរញ្ញវត្ថុ និងការប្រឆាំងការសម្អាតប្រាក់ (៥).ឥទ្ធិពលនៃលំហូរមូលធនលើប្រព័ន្ធធនាគារ និងស្ថិរភាពហិរញ្ញវត្ថុ (៦). វឌ្ឍនភាពនៃការចាប់ផ្តើមបង្កើតវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន និងការលើកម្ពស់ការប្រើប្រាស់ប្រាក់រៀល និង (៧). ប្រធានបទទាក់ទងមាត្រាទី៤ របស់មូលនិធិរូបិយវត្ថុអន្តរជាតិឆ្នាំ២០១៣ ។

ជារួម អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានវាយតម្លៃល្អពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា ជាពិសេស ចំពោះសមិទ្ធផលនានា ដែលធនាគារជាតិនៃកម្ពុជា ខិតខំរក្សាស្ថិរភាពថ្លៃនិង ស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុក្នុងរយៈពេលខ្លីនិងមធ្យមបានប្រសើរ និងបានជួយគាំទ្រដល់ កំណើនសេដ្ឋកិច្ចជាតិ ។

**២/- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** : ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេស សម្រាប់ពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ តាមរយៈការជួយរៀបចំឯកសារបច្ចុប្បន្នកម្ម យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងផ្តល់ជំនួយគាំទ្រកម្មវិធីឥណទាន សម្រាប់វិស័យហិរញ្ញវត្ថុ ជំហានទី៣ ដើម្បីធ្វើជាមាគ៌ាចង្អុលទិសអភិវឌ្ឍវិស័យហិរញ្ញវត្ថុ នៅកម្ពុជា ឱ្យកាន់តែស៊ីជម្រៅ និងមានកម្រិតសមាហរណកម្មខ្ពស់ ស្របតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ។

**៣/- ក្រុមប្រទេសអាស៊ាន (ASEAN)**: កិច្ចសហប្រតិបត្តិការអាស៊ាន និងអាស៊ាន+៣ បានដើរតួនាទីកាន់តែសំខាន់ខ្លាំងឡើង ក្នុងការធ្វើសមាហរណកម្មហិរញ្ញវត្ថុ រក្សាស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច ទាក់ទាញការវិនិយោគ និងរក្សាស្ថិរភាពហិរញ្ញវត្ថុនៅក្នុងតំបន់ ។ តាមរយៈ កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ប្រទេសជាសមាជិកបានចូលរួមយ៉ាងសកម្ម ក្នុងការ អភិវឌ្ឍទីផ្សារមូលធន សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ សេរីភាវូបនីយកម្មគណនីដើមទុន និងវេទិកាទីផ្សារមូលធនអាស៊ាន ។

**៤/- មជ្ឈមណ្ឌល SEACEN** : កិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល SEACEN មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវ ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ រូបិយវត្ថុ ធនាគារ និងការអភិវឌ្ឍសេដ្ឋកិច្ច សម្រាប់ពង្រឹងសមត្ថភាពមន្ត្រីធនាគារកណ្តាលក្នុងតំបន់។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា បានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំនានា ដែលរៀបចំ ដោយមជ្ឈមណ្ឌលស៊ាសិន សហការជាមួយធនាគារកណ្តាលជាសមាជិក ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានទទួលធ្វើម្ចាស់ផ្ទះ ក្នុងការរៀបចំសិក្ខាសាលារបស់មជ្ឈមណ្ឌល ស៊ាសិន សហការជាមួយមជ្ឈមណ្ឌលសិក្សាធនាគារកណ្តាលជប៉ុន លើកទី៧ ស្តីពី ការគ្រប់គ្រងនយោបាយរូបិយវត្ថុនិងម៉ាក្រូសេដ្ឋកិច្ច ចាប់ពីថ្ងៃទី២៥ខែមីនា ដល់ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ នៅខេត្តសៀមរាប ប្រកបដោយជោគជ័យ។

**៥/- ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone)** : ប្រតិភូ ធនាគារជាតិនៃកម្ពុជា តែងតែបានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារកណ្តាល នៃ ក្រុមប្រទេសនិយាយភាសាបារាំង (Francophone) ជារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរយោបល់

និងបទពិសោធន៍ ក្នុងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល ការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងកិច្ចសហប្រតិបត្តិការរូបិយវត្ថុ ។ កាលពីថ្ងៃទី៨-១១ ខែឧសភា ឆ្នាំ២០១៣ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានអញ្ជើញទៅចូលរួមសន្និសីទប្រចាំឆ្នាំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង លើកទី២០ នៅទីក្រុងវែសៃ ប្រទេសបារាំង ។

**៦/- សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA) :** ធនាគារជាតិនៃកម្ពុជាត្រូវបានមហាសន្និបាត ជ្រើសតាំងជាប្រធានសមាគមនេះសម្រាប់អាណត្តិរយៈពេល ២ឆ្នាំ ចាប់ពីខែមិថុនា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៤ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកពាក់ព័ន្ធនឹងវិស័យមីក្រូហិរញ្ញវត្ថុ និងហិរញ្ញប្បទានជនបទ ។ ក្នុងនាមជាប្រធានសមាគម ធនាគារជាតិនៃកម្ពុជា បានដឹកនាំប្រកបដោយជោគជ័យ នូវកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ លើកទី៦២ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។

**៧/- កិច្ចសហប្រតិបត្តិការទ្វេភាគី** មានការរីកចម្រើនជាលំដាប់ ។ យើងបានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ឆេក លុចហ្សំបួរ អាល្លឺម៉ង់ គណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ គណៈកម្មការបញ្ញត្តិកម្មធនាគារចិន អាជ្ញាធរបទប្បញ្ញត្តិប្រុងប្រយ័ត្នអូស្ត្រាលី និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ាននិងអាស៊ាន+៣ លើផ្នែកបណ្តុះបណ្តាលធនធានមនុស្ស និងផ្លាស់ប្តូរបច្ចេកទេស ។

**- គណៈអធិបតី**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងសម្រេចបានសព្វថ្ងៃនេះ បានមកពីការខិតខំប្រឹងប្រែងបំពេញការងារ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការចូលរួមសហការពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាត មេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍លម្អិត ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍធនាគារជាតិនៃកម្ពុជា ឱ្យរីកចម្រើននិងសម្រេចបានសមិទ្ធផលជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នា

ជាប្រពៃណីនេះតទៅទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលមួយថ្ងៃ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារដែលអនុវត្តកន្លងមក និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួន ឱ្យបានជោគជ័យនិងមានប្រសិទ្ធភាព ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឱ្យអង្គសន្និបាតរបស់យើងមានដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**